## ជំពូកទី៦

## អាថ៌កំបាំងក្នុងពែងកាហ្វេ

ភារម្យឱ្យនាងទុកកូនឡានពណ៌ក្រហមចោលនៅចំណតដដែលហើយបន្តដំណើរថ្មើរជើងតាមបណ្ដោយផ្លូវលំ ដែលចុះជម្រាលតាមពីក្រោយអធិការដ្ឋាន។ អាកាសធាតុតំបន់នេះ ត្រជាក់ល្អ ថែមទាំងស្រទោរស្រទំពេញដោយសម្រស់។

ដែនដីក្រហមដ៏សម្បូរជីវជាតិប្រាកដណាស់បានរំញោចចិត្តនាងឱ្យនឹកភ្នកដល់រសកាហ្វេដែលប៉ូលិសកំពុងអួត។

កូនតៀមមួយលេចឡើងនៅជ្រុងផ្លូវដែលចម្ងាយមិនដល់ ៥០ម៉ែត្រពីដើមផ្លូវនេះទេ។ តុឬស្សីពីរបីនិងស្លាកតូចមួយ «កាហ្វេប៉ាស្រីភា» អាចមើលឃើញសូម្បីតែទើបនឹងដើរបន្ថែមបានបន្តិច។

«បរិយាកាសគួរសម!»

នាងនិយាយ។ អធិការទាញកៅអីមួយសម្រាប់នាង ហើយគេអង្គុយចុះពត់ខ្លួននៅនឹងមុខស្រីស្អាតដោយស្ងាបផង។

«ពូ! កាហ្វេចាស់បន្តិច យប់មិញគេងមិនលក់សោះ!»

បុរសសក់ល្បាយ សើចពីក្រោយទូកញ្ចក់។ គាត់នោះហើយដែលជាប៉ាស្រីភាមើលទៅ។

«មានភ្ញៀវមេ?!»

បុរសម្ចាស់ហាងសួរទាំងដៃចាប់ផ្ដើមធ្វើការរបស់គាត់។

«នាំអ្នកភ្នំពេញមកភ្លក្សកាហ្វេប្រេនៗរបស់ពូ!»

នាងញញឹមកំដរទឹកមុខរួសរាយនៃបុរសចំណាស់ ហើយងាកមករកនាយប៉ូលិសដែលបន្តស្ងាប។ គេនោះលើកបាតដៃធំរបស់ខ្លួនបិទបាំងមាត់ខ្លួនពីកែវភ្នែកនាងក្រមុំចំពោះមុខ តែកាយវិការគេគឺហាក់ស្រស់ស្រាយជាងកាលពីក្នុងការិយាល័យ។

«ឈ្មុយមិនអន់ទេ! អ៊ំ នៃពូ របស់ខ្ញុំមិនដាក់ស្ករទេ »

ឃើញនាងបន្ថែមពាក្យសរសើរ បុរសចំពោះមុខងក់ក្បាល និយាយបន្ទរះ

«បាទ! ឧកញ៉ាវុទ្ធីក៏ធ្លាប់មកពិសានៅនេះដែរ!»

នាងប្តូរទឹកមុខ។ បុរសវាចាបន្ថែម៖

«ជឿអត់?»

«ពូខ្ញុំនិងលោក ធ្លាប់ជួបគ្នា?»

«ញឹកញាប់!»

គេឆ្លើយរហ័សរហួនតែចម្លើយជាចំណុចដ៏ភ្ញាក់ផ្អើលសម្រាប់នាង។

«ខ្ញុំមិនដែលដឹងទេ!»

«ធីតាមិនបានសួរ!»

«អូខេ! កំហុសខ្ញុំ!»

«ខ្ញុំមិនដាក់បន្ទុកមនុស្សគ្រាន់តែរឿងស្រាលប៉ុណ្ណឹងទេ! ឈប់ដាក់បន្ទុកខ្លួនឯងទៅ!»

ធីតាទទួលអារម្មណ៍ថា គេនេះមានចេតនាចង់បន្ទោសនាងអំពីការជជីកបន្តសំណុំរឿង ឬហៅម្យ៉ាង គេអាចចាត់នាងបញ្ចូលចំណោមមនុស្សឆាប់រំជួលអារម្មណ៍ (Sensitivity)។

បុរសលើកថាសមកដល់ជាមួយកាហ្វេពីរពែងធំ និងតែក្តាប់ពីកែវធំដែរ។

នាងរភ្នែក សម្លឹងភេសជ្ជៈហើយញញឹមជាសញ្ញាអរគុណម្ចាស់ហាង។

«សាកមើលចុះ! កាហ្វេនេះប្រើសម្រាប់អ្នកភ្នំពេញថ្ងៃដំបូង!»

នាងលើកចិញ្ចើមភ្ញាក់ផ្អើល ៖

«យី មាន Promotionទៀត!»

ប៉ូលិសញញឹមហើយលើកពែងខ្លួនមកក្រេប។ នាងធ្វើតាមតែនាងស្រង់ក្លិនសិនទើបចាប់ផ្តើមក្រេបតិចៗ ។

នាងធ្វើមុខល្វីង ក្រោមស្នាមសើចនៃប៉ូលិសយុត្តិធម៌។ បុរសនេះទំនងដឹងហើយថា កាហ្វេធម្មជាតិល្វីងកម្រិតណាប្រសិនគ្មានជំនួយពីគ្រឿងផ្សំ គេនេះទំនងជាសាកល្បងនាង?

នារីគិតហើយសម្លក់៖

«មានអីសប្បាយនឹងសើចទៅ? ល្វីងណាស់!»

«លេបចូលដល់បំពង់កនឹងក្លាយជាផ្អែមឈ្ងុយវិញ!»

នាងធ្វើតាម ហើយបន្តធ្វើទឹកមុខប្រតិកម្មចំពោះរសជាតិ៖

«ឈ្ងុយមែនតែល្វីងមិនដូរទេ! ផ្អែមពីណាមក!»

«បើគិតថាផ្អែម គឺវាផ្អែមហើយ!»

គេនិយាយមកទៀតធ្វើឱ្យនាងរិះគិតបណ្ដើរតបតបណ្ដើរ៖

«ប៉ូលិសស៊ើបអង្កេតក៏ចេះលេងពាក្យជាប្រស្នាដែរ?!»

«ពាក្យពូនាងបន្សល់ទុក!»

ធីតាស្រពោន រំឭកដល់បុរសចំណាស់ជាអ្នកមានគុណ។ នាងដាក់ពែងចុះហើយបង្ហាញនូវភាពស្មុគស្មាញក្នុងកែវភ្នែកហាក់ទុកពេលផ្ទៀងស្ដាប់អធិការ ភារម្សនិយាយបន្ត៖

«គាត់ពូកែពិសាកាហ្វេណាស់! ដំបូងខ្ញុំចេះពីគាត់ ហើយពាក្យនេះគឺគាត់ប្រាប់ខ្ញុំ!»

នាងទន្ទេញរអ៊ូម្នាក់ឯង៖

«បើគិតថាផ្អែម គឺវាផ្អែមហើយ»

អធិការតាមសម្លឹងនាងដោយស្ងាត់ស្ងៀមព្រោះគេសម្គាល់ឃើញជាបណ្ដើរៗថា បុរសរងគ្រោះនិងក្មួយស្រីមានមនោសញ្ចេតនាជ្រៅឡើងៗតាមរយៈការនិយាយជាមួយនាង។

ស្រីស្អាតងើបមុខមកភ្លាមជាមួយសំណួរ៖

«មុនកើតហេតុ លោកបានជួបជាមួយគាត់ចុងក្រោយទេ?!»

«ប្រាកដណាស់! ខ្ញុំជាភ្ញៀវក្នុងពិធីនោះ! ថ្ងៃដែលគាត់ធ្លាក់ពីជាន់ទីមួយមក»

គេឆ្លើយដូចធម្មតាតែនារីអ្នកស្ដាប់ឯណោះវិញ នាងសែនអន្ទះសាចង់ដឹង។

**ជំពូកទី៧**

**ដៃគូពិភាក្សា**

«នៅថ្ងៃនោះ ជាទម្លាប់ធម្មតារបស់គាត់ ពូវុទ្ធីបានឈរផ្អែកបង្កាន់ដៃជណ្ដើរបន្ទប់ទទួលភ្ញៀវហើយគាត់ សម្លឹងផ្ទៃសួនច្បារខាងក្រៅ ពេលនិយាយទូរសព្ទ! គាត់ហាក់កំពុងនិយាយរឿងសំខាន់អ្វីមួយ បានជាគាត់ក្រោកចោលតុជប់លៀង ដែលមានភ្ញៀវសំខាន់ៗជាង២០នាក់កំពុងមានវត្តមាន!»

នាងនិយាយដោយស្រងូត ធ្វើឱ្យអ្នកនៅចុងម្ខាងនៃទូរសព្ទសម្ងំបន្តរង់ចាំស្ដាប់។

«អធិការប៉ូលិសភារម្យនិយាយថា ខ្លួនគេផ្ទាល់ក៏បាននៅទីកើតហេតុក្នុងនាមជាភ្ញៀវម្នាក់របស់ពូដែរ! ពួកគេស្គាល់គ្នា! ប៉ូលិសមានហេតុផលច្រើនក្នុងការបិទចោលសំណុំរឿងធ្វើឃាតមកជាគ្រោះថ្នាក់ចៃដន្យ ដោយយោងតាម របាយការណ៍នៃអ្នកជំនាញវេជ្ជសាស្ត្រ លទ្ធផលការប្រមូលភស្តុតាងនៅកន្លែងកើតហេតុ និងដំណើរការតាមរយៈប្រវត្តិលោកពូ! និយាយឱ្យខ្លីធាតុផ្សំនៃដំណើរការស៊ើបមិនថា បុព្វហេតុពេលវេលានិង ការធ្វើតេស្តនៅមន្ទីរពិសោធន៍ ការវិនិច្ឆ័យតាមប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គេមានហេតុផលគ្រប់គ្រាន់ក្នុងការបដិសេធថានេះមិនមែនជាករណីឃាតកម្ម!»

និយាយទូរស័ព្ទផង ដៃស្រីស្អាតរវេចង្កូតឡានបែបរវើរតាមផ្លូវកែងតូច ក្នុងល្បឿនដ៏ឃើត ពុំនោះទេ នាងនឹងបង្ករឿងធំមិនខានព្រោះកង់មួយបានលយក្បាលមកដល់ហើយបាត់ជំហរ។

ប្រសិនបុរសអ្នកជិះមិនមែនមានជើងវែងជង្គង់មាំ ម្ល៉េះសមទាំងជំនិះនិងម្ចាស់ដួលរលេទៅលើដីទៅហើយ។

«ខ្ញុំសុំទោស! ហើយមានត្រូវត្រង់ណាដែរអត់?!»

នាងស្ទុះទៅក្បែរម្ចាស់កង់ដែលនៅប្រឹងទប់ជំហរ។ គេនេះដូចជាធ្លាប់ស្គាល់?

អ៊ូ មែនហើយ គេហ្នឹងសោះ។ នាងនឹកឃើញភ្លាមទាំងហួសចិត្តឯមាត់ក៏ភ្លាត់ហៅ៖

«ពេទ្យសាន?»

បុរសជាពេទ្យទំនងជាមើលស្គាល់នាងតាំងពីចម្ងាយមកហើយបានជាទឹកមុខគេ មិនបានបង្ហាញថាមាន ចិត្តទូលាយលើកលែងកំហុសឱ្យនាងទេ ក៏ប៉ុន្តែទោះយ៉ាងណាសម្ដីទន់ភ្លន់របស់គេ បានបញ្ចេញមកផ្ទុយពីទឹកមុខ។ គេមិនឆ្លើយនឹងនាងទេបែរជាមានសំណួរដែរ៖

«ទៅណាប្រញាប់ម៉េះ?»

«ខ្ញុំមកពីជួបអធិការប៉ូលិស! ខ្ញុំសុំទោសម្ដងទៀត! ខ្ញុំស្លុងអារម្មណ៍ពេកបានជា...!»

គេនោះបណ្តើរកង់ទៅមុខត្រឹកៗ។ នារីតាមមើលដោយទឹកមុខបារម្ភ ហើយក៏ឃើញថាកង់ក្រោយគេរៀចរ័ត បានជាគេមិនអាចជិះបន្តបាន។ ស្រីស្អាតមានអារម្មណ៍សោកស្តាយស្ងាត់ៗក្នុងចិត្តចំពោះចរាចរណ៍ដ៏ធ្វេសប្រហែសរបស់ខ្លួនទោះបីខាងអ្នករងគ្រោះមិនបាននិយាយអ្វីក្តី។

នាងបែរទៅមើលរថយន្តខ្លួនឯងហើយចុចបញ្ជាចាក់សោរ មុនពេលរត់ត្រុកទៅតាមគេពីក្រោយ។

«អ្ហូ! ចប់ហើយ! ដៃពេទ្យសានរបួសហើយ!»

នាងនិយាយទាំងក្តុកក្តួលចិត្តខណៈក្រឡេកឃើញដៃម្ខាងស្តាំដែលគេកំពុងកាន់បណ្តើរកង់នោះហាក់ដាមឈាមប្រលាក់រីមៗ។ អាវគេពណ៌ផ្ទៃមេឃស្តើងផង ម្លោះហើយ មិនពិបាកសម្រាប់នាងក្នុងការសម្គាល់ឃើញស្លាកស្នាមរបួសទេ។

ដើមម៉ែសាក់ដុះអមដងផ្លូវ ធ្វើឱ្យនាងដឹងខ្លួនថា ទីនេះនៅក្បែរបន្ទប់ព្យាបាលរបស់គេដែរហើយ។ ចិត្តនាងធូរបន្តិចវិញ ហើយសំណូមពរ៖

«អូខេ! ខ្ញុំរុំរបួសឱ្យ!»

បុរសនេះមិនមាត់ តែគេក្រឡេកមកសម្លឹងនាងទាំងមុខស្មើ ធ្វើឱ្យនារីអ្នកកាសែតសង្កេតឃើញឫកពាមាំទាំគួរឱ្យក្រែងចិត្តរបស់គេ។ ទោះបីយ៉ាងណា កែវភ្នែកគេមុតណាស់។ ម្តងនេះ មួយក្រឡេករបស់គេហាក់ធ្វើឱ្យនាងចេះចាញ់ប្រាប។

«ប្រុសស្អាតឯណាឫកម៉េះ! និយាយមួយម៉ាត់មានធ្លាក់មាស ឬត្បូងរតនគីរីចេញអស់ប៉ុន្មានគ្រាប់?!»

នាងគិតទាំងទោមនស្ស ចំណែកថ្ពាល់ចេញចំហាយក្តៅៗដែលខ្លួនឯងក៏ដឹងថាកំពុងតែគិតអ្វីអំពីឫកពាទាក់ទាញរបស់គេ។

«ចេះរុំរបួសដែរ?!»

គេដើរបណ្តើរនិយាយសួរបកតិចៗបណ្តើរ ធ្វើឱ្យនាងងើបមុខឡើងមកវិញសម្លឹងសារជាថ្មីភ្លាម។ អស្ចារ្យហើយ! និយាយទាំងបែរខ្នង ប្រុសម្នាក់នេះឫកពាណាស់គេអាងអីទៅ?

រាងកាយគេពេលឈប់ដំណើរ ដាក់ជន្ទល់កង់គឺខ្ពស់ស្រាវ និងរឹងមាំ។ សំណួរគេ នៅបុកទង្គិចចិត្តនាងនៅឡើយ។ ពិតណាស់នាងមិនចេះទេ ថែមទាំងខ្លាចក្នុងការលាងរបួសផង។ និយាយរួមគឺមិនដែលបានធ្វើ មិនដែលបានសាក។ ទោះយ៉ាងណា ធីតាក៏ចេះនិយាយកុហក៖

«ស្មានតែមានតែពេទ្យ បានចេះលាងរបួស?!»

បុរសនេះសើចខឹករង្គើស្មាគេតិចៗ បង្កើនសម្រស់បុរសភេទដែលអាចទាញចំណាប់អារម្មណ៍បេះដូងនារីបានដោយមិនពិបាក។

ទីបំផុតទៅ នារីនេះនៅតែត្រូវគេឱ្យអង្គុយដូចជាភ្ញៀវ រង់ចាំមើលគេខ្លួនឯងរុំរបួសដៃដោយហ្មត់ចត់និងទន់ភ្លន់។

«និយាយម្តងទៀតបានអស់ចិត្ត! ខ្ញុំសុំទោសពិតមែន!» នាងពោលស្រាលៗ។

«គង់តែឱ្យទោសទេ!»

ពេទ្យឆ្លើយតិចៗមុនពេលងៀងកន្ទុយភ្នែកមើលមុខនាង។ ធីតាដែលត្រូវអំណាចកន្ទុយភ្នែកបុរសដាក់សញ្ញាសម្ងាត់ជាកិច្ចខឹដងហើយនោះ គាប់ជួនចិន្តាអង្គឯងក៏កំពុងងឿងឆ្ងល់ ចង់ដឹង ចង់ឮអំពីបេះដូងជ្រៅសន្លឹមនៃបុរសមានជីវិតស្ងាត់ស្ងប់កណ្តាលរុក្ខវិថីផង នាងចាប់ផ្តើមមានអារម្មណ៍ចម្លែក។

«បើមិនកៀរគេរបួស ក៏មិនចាប់អារម្មណ៍ថាគេនេះជាប្រុសស្អាតដែរ!»

នាងលបលួចគិតផង គេចភ្នែកចេញពីកំភួនដៃសរសៃសសូងដ៏ទាក់ទាញរបស់នាយ និងធ្វើមិនឮចំពោះពាក្យស៊កសៀតផង។

«ញ៉ាំទឹកដែរអត់?!»

គេសួរទាំងក្រោកឡើងទៅរៀបចំទុកដាក់របស់របរទៅក្នុងប្រអប់បរិក្ខារវិញ ស្របពេលនាងឆ្លើយ៖

«អត់អីទេ! ទើបញ៉ាំកាហ្វេហើយពីរកែវឯណោះ!»

ស្រាប់តែគេតបមកវិញដោយមិនងើបមុខ៖

«ផ្ទះប៉ាស្រីភា?!»

ធីតាបើកភ្នែកធំៗ ទាំងមាត់ញញឹមសួរវិញ៖

«ហាងគាត់ល្បីម៉េះ?»

«បាននិយាយគ្នារឿងអីខ្លះ?!»

«ភាគច្រើនរឿងលោកពូខ្ញុំ!»

ពេទ្យថយមកអង្គុយក្បែរនាងដោយទឹកមុខស្រទន់។ ទោះគេមិនញញឹមក៏សង្ហាស្រេចទៅហើយ ជាមួយកែវភ្នែកធំមុត និងច្រមុះតូចស្រួច។ បបូរមាត់ដូចស្នែងក្របីនៃបងពេទ្យសង្ហា នៅមិនទាន់អាចផ្ទៀបជាមួយទ្រូងធំមាំរបស់គេ ដែលលាត់ដៃអាវចេញអស់មួយចំហៀងដៃនោះផង។ ឥឡូវមកអង្គុយក្បែរគ្នាយ៉ាងនេះ ស្រីឯណាមិនរសាប់ចិត្ត។

នាងនៅស្ងៀមជាមួយទឹកមុខក្រហមព្រឿងៗ។ ដុកទ័រជនបទក៏មិនមែនល្ងង់ខ្លៅមើលមិនឃើញរលកបេះដូងស្រីស្អាតចំពោះមុខទេ គ្រាន់តែចរិតប្រុសស្អាតគឺពូកែលាក់គំនួច។

ទោះគេមិនញញឹមតែនាងឃើញគំនួចពេញចិត្តនៅលាក់បង្កប់តាមចុងមាត់ទាំងសងខាង។ ម្ដងម្កាលគេហាក់ខាំធ្មេញជាសញ្ញាគ្រឹតនឹងសម្រស់នាងជាសម្ងាត់ដូចគ្នា។

«យើងមកលើកនេះ រកមិនឃើញឃាតកបែរជាឃើញម្ចាស់បេះដូងទៅវិញដឹង?!»

សំណួរទាំងនេះប្រសិនលាន់ពីក្នុងចិត្តមកក្រៅ ដល់ថ្នាក់ឱ្យនាយពេទ្យឮបាន មិនដឹងយកមុខទៅទុកនៅឯណាទេយើង។

នាងគិតទាំងខំរកនឹកអ្វីមកនិយាយបន្លប់បរិយាកាស។

សំឡេងគេជ្រែកមកមុនដែលនាងរកនឹកឃើញទៅទៀត៖

«ប៉ូលិសយុត្តិធម៌ ប្រាប់ធីតារឿងអីខ្លះ?!»

ទើបនឹងចាប់អារម្មណ៍ថា គេនេះស្គាល់ឈ្មោះខ្លួន ហើយហៅដូចជាផ្អែម ខុសអ្នកដទៃផង។ នាងឆ្លើយតបវិញ ព្រោះអរដែលបានគេនាំប្រធានបទចាកចោលកំណាត់ច្រាំងរ៉ូមែនទិច៖

«ម្នាក់ហ្នឹង ស្អីក៏មិននិយាយដែរ! គង់តែមានថ្ងៃទេ!»

ទីបំផុតនាងឃើញធ្មេញសត្រឹមរបស់គេហើយ ព្រោះគេកំពុងសើចស្ងាញដោយគ្មានសំឡេងសំណើចព្រោះតែឮចម្លើយរបស់នាង។ នាងដឹងថាគេកំពុងផ្ដោតអារម្មណ៍លើសម្ដីនាងដែលរំឭកអំពីអធិការភារម្យ។

ធីតាបន្ត៖

«ខ្ញុំទៅដល់ទៅពីរដងហើយ! ឯកសារគេមិនឱ្យ របាយការណ៍លម្អិតគេមិននិយាយ គេទៅនាំនិយាយពីរឿងល្ងាចកើតហេតុតែប៉ុណ្ណឹង!»

ស្នាមញញឹមលើមាត់បុរសពេទ្យធ្លាក់ចុះមកវិញទំនងជាគេនឹកឃើញដល់ពូនាង។

គេបន្លឺតិចៗ៖

«ស្ដាយ! ល្ងាចនោះខ្ញុំទៅដល់យឺតពេលទៅហើយ!»

នាងស្រពោនហើយឈ្ងោកមុខ។ បុរសពេទ្យនិយាយបន្តទៀត៖

«រឿងហេតុកើតឡើងចៃដន្យពេក ម្នាក់ៗទទួលយកមិនបានទេ!»

នាងងើបមុខសម្លឹងគេ។ ធីតាយល់ហើយ ដែលគ្រប់គ្នាជឿតាមគំនិតមន្ត្រីប៉ូលិសហើយទុកថាពូខ្លួនស្លាប់តាមចំណារព្រហ្មលិខិត។ ទាំងនេះបង្ខំឱ្យមុខនាងកាន់តែស្រពោនឡើងៗ សឹងក្លាយមកជាមិនសប្បាយចិត្ត។

«ម្នាក់ៗគិតថារឿងហេតុសាមញ្ញៗ! ចៃដន្យអីអញ្ចឹងអ្វី?!» នាងរអ៊ូទោមនស្ស។

បុរសពេទ្យងើបមុខសម្គាល់កិរិយានាង ។ គេសម្លឹងផ្ដោតលើផ្ទៃមុខដែលកំពុងសម្លឹងមកនាយដៃរក្នុងន័យការពារគំនិតនាងដែលទើបនឹងបន្លឺនេះថា នាងគ្មានថ្ងៃអស់ចិត្តអំពីហេតុការណ៍ល្ងាចនោះឡើយដរាបណា គ្មានការសើបសួរគ្រប់ជ្រុងជ្រោយ។

«ចុះធីតាកំពុងគិតអី?!»

«ពូខ្ញុំអាចត្រូវអ្នកណាម្នាក់រៀបចំអ្វីមួយធ្វើបាបគាត់!»

នាងឆ្លើយភ្លាម ច្បាស់ៗម៉ាត់ៗ ទោះជានាងមិននិយាយឮៗក៏ដោយ។

ទឹកមុខបុរសគូសន្ទនាផ្លាស់ប្ដូរ តែគេមិនមាត់មិនក ហាក់នៅជំអក់រង់ចាំស្ដាប់បន្តទៀត។

នាងសម្លឹងគេវិញដោយកែវភ្នែកក្រឡង់។ ទំនងជាសម្ដីនាងធ្វើឱ្យគេភ្ញាក់ភ័យ ឬតឹងតែង តែនាងមិនស្ដាយក្រោយទេក្នុងការការពារជំហរពិតរបស់ខ្លួន។ នារីនិយាយផ្ទួនៗ៖

«ជណ្ដើរនោះអាចត្រូវបាក់មុនពេលគាត់ទៅឈរផ្អែក! វាជាឃាតកម្មដែលមានការគ្រោងទុក!»

ទឹកមុខអ្នកស្ដាប់កាន់តែប្រែប្រួលមួយទំហឹង។ ភាពមុតថ្លាបង្ហាញចេញច្បាស់ៗក្នុងកែវភ្នែកទាំងសងខាងនៃបុរសពេទ្យ បញ្ជាក់ថាគេយកចិត្តទុកដាក់ស្ដាប់គំនិតនាង។

ធីតាខំមាត់ទប់ទល់នឹងការឈឺចាប់ក្នុងចិត្ត តែតំណក់ទឹកបានលេចមកផ្សើមរំលើបកែវភ្នែកទាំងសងខាងរបស់នាង។ បុរសនេះហាក់ចង់បន្ថយកំសួលចិត្តគូសន្ទនា បានជាគេសម្រួលសំឡេងហើយនិយាយវិញ៖

«ក្រុងប៉ូលិសបិទសំណុំរឿងនេះហើយ! គេថែមទាំងបញ្ជាក់ថា....»

«ខ្ញុំនឹងរកបានភស្តុតាងធ្ងន់ៗមកតវ៉ាជាមួយពួកគេនោះឆាប់ៗនេះ!»

នាងតបវ៉ាវិញរកតែខាងប្រុសបញ្ចប់ប្រយោគមិនទាន់។

ភាពម៉ឺងម៉ាត់រឹងមាំស្រាប់តែបង្ហាញចេញមកលើឫកពានារីទីក្រុងជំនួសឱ្យថ្ពាល់ក្រហមពោរពេញទៅដោយក្លិនស្នេហ៍កាលមុននេះប៉ុន្មាននាទី។ ការនេះច្រានឱ្យបុរសម្ចាស់ផ្ទះថយខ្លួនផ្អែកទៅនឹងបង្អែកកៅអី ហាក់បានស្រងាកចិត្តនឹងព័ត៌មានថ្មីៗដែលទើបបន្លឺចេញពីមាត់នាង។

«មនុស្សស្លាប់មិនទាន់បានមួយខែ ប៉ូលិសយុត្តិធម៌ក៏ព្រមបញ្ចប់សំណុំរឿង! ខ្ញុំមិនយល់ទេប៉ូលិសស្រុកនេះ!»

ដល់ពេលដែលខាងប្រុសលែងនិយាយតវ៉ាគឺនៅអង្គុយអត់ធន់ស្តាប់នាង ឱ្យនាងបញ្ចេញកំហឹងចិត្ត។ សន្ធឹករថយន្តបោលមកពីចំងាយសឹងថា ផ្អើលអស់ស្លឹករុក្ខជាតិនិងពពួកហ្វូងសត្វតូចធំ។

នាងឃើញពេទ្យសានរភ្នែកសម្លឹងទៅដានធូលីហុយកំដរផ្លូវ ពីក្រោយវត្តមានរថយន្តដ៏ទំនើបពណ៌ខ្មៅស្រិល។ វាចាគេលាន់មកតិចៗប្រាប់នាង៖

«ឡានម្តាយមីងថ្លៃរបស់ធីតា! លោកជំទាវវត្តី ភរិយាឧកញ៉ាវិទ្ធី!»

នាងបែរក្រោយឃឹតៗ សម្លឹងទៅកាន់ទីនោះ។

**ជំពូកទី៨**

**លោកជំទាវវត្តី**

នៅពេលមនុស្សខ្លះបានហៅគាត់ថា សេដ្ឋីនីភ្នំពេញ ការនិយាយអេចអូចពីក្រោយខ្នងគាត់ នៅជុំវិញទីដែលគាត់ធ្លាប់រស់នៅ បានក្លាយជារឿងធម្មតា។ ជំទាវវត្តី មានវ័យប្រមាណ៥០ឆ្នាំក្រាស់ហើយ ប៉ុន្តែធីតាអាចនឹងមានអារម្មណ៍ចង់ហៅគាត់ថាបងទៅវិញជាមួយរូបសម្រស់ក្មេងខុសវ័យរបស់គាត់។

លោកជំទាវមានរាងរាវ ដូចអ្នកបង្ហាញម៉ូតស្រុកបារាំង ពេលឈានចុះមកពីរថយន្តដ៏ទំនើបផងសឹងថាជាទិដ្ឋភាពដែលសូម្បីជំទាវចរិយាជាកូនប្រសា សឹងមិនអាចផ្គូផ្គងជាមួយគាត់បាន បើនិយាយអំពីភាពទាក់ទាញ។

ដោយសារខានឃើញគាត់យូរពេកផង ធីតាយកចិត្តទុកដាក់ចំពោះស្ត្រីរូបនេះជាជាងអ្នកបើកឡានធាត់កន្ទួករបស់គាត់។ រហូតដល់ជំទាវវត្តីហុចកាបូបយួរទៅឱ្យជននោះយកទៅទុកទើបនាង ភ្ញាក់អារម្មណ៍រវេីរវាយតាមសម្លឹង អ្នកបើកបរដែលមុននេះ វាតទីបង្កើតធូលីហុយផ្អើលខេត្ត។

«ធីតា មកដល់យូរហើយ?!»

សម្តីស្រទន់របស់ស្ត្រីម្ចាស់ផ្ទះ បានដាស់នាងឱ្យឱនសំពះតាមទម្លាប់។

«ចាំអ្នកមីង កាលពីល្ងាចមិញ!»

«ឡើងមកពីស្រុកបារាំងភ្លាម មករតនគីរីតែម្តង?!»

គាត់សួរបញ្ជាក់បន្ថែមដោយញញឹមស្ងួតស្វាគមន៍នាង។

«ចាំអត់ទេអ្នកមីង! កូនចូលធ្វើការនៅភ្នំពេញជិតពីរខែហើយ»

គាត់លើកចិញ្ចើមជាសញ្ញាភ្ញាក់ផ្អើលសរសើរហើយពោលបន្ត៖

«មកហូលីដេ?!»

«ខ្ញុំឈប់ធ្វើការនៅភ្នំពេញហើយ!» នាងថាទាំងញញឹមមិនសូវសមដាក់គាត់។

«ហើយមកស្នាក់នៅឯណេះ ប្រហែលជាយូរដែរអ្នកមីង!»

«ស្វាគមន៍ជានិច្ច!» ស្ត្រីអភិជនឆ្លើយទាំងញញឹមស្រស់ ហើយមកកៀកកនាំនាងចូលទៅក្នុងផ្ទះ។

បាយថ្ងៃត្រង់ផ្ទះនេះ ហាក់មានសភាពអ៊ូអរជាងភាពក្រៀមក្រោះកាលពីល្ងាច។ និស្សិតស្រីមកពីបរទេស ក្នុងនាមជាអ្នកមករកយុត្តិធម៌ជូនពូខ្លួន ទោះបីត្រូវអ្នកផងទទួលដូចភ្ញៀវពិសេស ក៏ប៉ុន្តែនាងមានគំនួចជាច្រើនលាក់ទុកក្នុងចិត្ត។

សភាពជំទាវវត្តីដែលជាភរិយារបស់លោកពូខ្លួន និងជំទាវចរិយាដែលជាភរិយាក្មេងខ្ចីនៃបងប្រុសជីដូនមួយខ្លួន មិនបានធ្វើឱ្យចិត្តនារីអ្នកកាសែតបានធូរស្រាលទេ។ ទម្លាប់ពួកគេ កាយវិការសម្តីសំដៅជាមនុស្សសង្គមជាន់ខ្ពស់ និយាយតិចៗ លាក់លៀមច្រើន មិនបញ្ចេញអារម្មណ៍ពិត មិនរួសរាយ ក៏មិនកោងកាច ធ្វើឱ្យនាងមានអារម្មណ៍រងសម្ពាធ។

«ឯណាបងភិន?!»

ម្ហូបជាច្រើនមុខ រៀបចំពោរពាស តែនៅជុំវិញតុដ៏វែងមានតែមនុស្សស្រីបីនាក់ ពិតជាមិនសមមែន។

ជំទាវងាកសួរកូនប្រសាស្រីរកមើលបុរសដែលធីតាចាំបានថា គាត់មានបញ្ហាសុខភាពកាលពីម្សិល។ ជំទាវចរិយារៀបរយខ្លួន ដោយលាកន្សែងដែលប្រើសម្រាប់ទ្រអាហារកំពប់ មកក្រាលគ្របលើភ្លៅបណ្ដើរឆ្លើយនឹងសំណួរម្ដាយក្មេកបណ្ដើរ៖

«ពូសំភិនគាត់មិនស្រួលខ្លួនពីរបីថ្ងៃហើយ! គាត់ពិសាបបរនិងលេបថ្នាំក្នុងបន្ទប់!»

ជំទាវហាក់យកចិត្តទុកដាក់ គាត់សួរដោយដាក់ស្លាបព្រាចុះ៖

«មានហៅពេទ្យសានមកពិនិត្យឬនៅ?!»

ធីតាមិនឆ្លើយអ្វីជំនួសពេលឃើញចរិយាងក់ក្បាលយឺតៗ។ នាងដឹងថាបងថ្លៃមិនចង់រំឭកហេតុការណ៍ពូសំភិនដួលម្នាក់ឯងម្សិលមិញក៏ហីទៅចុះ។

ជំទាវដកដង្ហើមធំហើយចាប់ផ្ដើមការបរិភោគធ្វើដូចនេះជាកាតព្វកិច្ចដែលគាត់មិនចង់ ក៏ត្រូវតែអនុវត្ត។ គាត់និយាយដោយសម្រួលទឹកមុខ៖

«ធីតា ញ៉ាំឱ្យច្រើនទៅកូន! ម្ហូបល្អៗណាស់ មីងកុម្ម៉ង់មកពីភ្នំពេញ!»

«ចា៎អ្នកមីង!»

ធីតាឆ្លើយដោយដៃចាប់ផ្ដើមលើកសម និងស្លាបព្រា។ ស្ត្រីចំណាស់លូកចាប់ម្ហូបមួយមុខពេញដោយបន្លែមកដាក់ឱ្យនាងជាមួយវាចាបន្ថែម៖

«នៅឱ្យបានយូរ! ផ្ទះយើងមនុស្សតិចណាស់!»

ធីតាវេភ្នែកគិតហើយងើបមុខសម្លឹងជំទាវទាំងទ្វេ ម្ដងម្នាក់មុនពេលសម្រេចចិត្តនិយាយ៖

«ខ្ញុំប្រហែលនៅច្រើនខែ! ខ្ញុំកំពុងរកការងារធ្វើនៅរតនគីរីនេះដែរ!»

ជំទាវម្ចាស់ផ្ទះហាក់អាក់កាយវិការចាប់ម្ហូប តែបន្ទាប់មកគាត់ញញឹមសន្សឹមៗព្រោះឃើញថា នាងកំពុងតាមដានប្រតិកម្មរបស់គាត់។ ធីតាក៏ចង់ដឹងដែរថា សម្ដីខ្លួនអាចធ្វើឱ្យស្ត្រីដ៏មានទ្រព្យធនទាំងទ្វេទើសទាល់ដែរឬអ្វី។

«នៅលេងក៏នៅទៅ ចុះចង់ធ្វើការអីទៀត? មិនគិតរករៀនអីបន្ថែមទេ?!» ជំទាវសួរស្រាលៗ។

ពួកគេទំនងជាគិតថា នាងមានលុយមរតកក៏សមរម្យ ចំណេះដឹងក៏ទាន់ទីផ្សារ មិនសមណាមកស្វែងរកការងារធ្វើនៅខេត្តតូចមួយតំបន់ដាយដែនបែបនេះ?

យ៉ាងណាក្ដី នាងមិនរវល់ពេកទេចំពោះអារម្មណ៍ពួកគេ។ នេះជាផ្ទះលោកពូនាង ហើយនាងជាញាតិជាសាច់ឈាមតែមួយគត់របស់គាត់ ឥឡូវទោះគាត់លែងនៅ នៅតែគ្មានអ្នកណាមានសិទ្ធិរាំងនាងពីការចេញចូលផ្ទះនេះដដែល។ នេះជាអ្វីដែលនារីអ្នកកាសែតកំពុងប្រាប់ខ្លួនឯង។

«ធីតាចង់ធ្វើការអី?!» ចរិយាសួរឡើងម្ដង។

«អត់មានគោលដៅទេអ្នកបង! ខ្ញុំចង់រៀនអនុវត្តផ្ទាល់ខាងគ្រប់គ្រងសណ្ឋាគារ ឬ អាចខាងធ្វើចម្ការផងក៏ថាបាន!»

សំឡេងអ្វីមួយបោលទង្គិចកម្រាលថ្មម៉ាប លាន់ឆាំងពញ្ញាក់អ្នកទាំងបីឱ្យចាកចេញពីភាពស្ងប់ស្ងៀមងាកទៅសម្លឹង។ ស្ត្រីម្នាក់មានរាងធាត់និងទាបទ្រនាប់ ធីតាមិនដែលស្គាល់ពីមុនមកទេ កំពុងឈរឆ្លេឆ្លានៅជ្រុងបន្ទប់នេះ ហើយដៃគាត់មានកាន់ថាសមួយមកផង។ រូបរាងនិងការតុបតែងរបស់គាត់សមជាអ្នកជំនួសដៃជើងក្នុងផ្ទះបាយ ហើយហាក់ដូចកំពុងបន្តលើកអ្វីៗមកបម្រើដល់តុអាហារនេះឯង។ ស្លាបព្រាបុរាណពណ៌ស្ពាន់ នៅកម្រើកលើកម្រាលឥដ្ឋ ក្បែរជើងគាត់នៅឡើយ ហាក់ប្រាប់ថាមុននេះអ្វីមួយ បានធ្វើឱ្យគាត់ភ្ញាក់រហូតរបូតវាធ្លាក់មកលើឥដ្ឋ?

«អ្នកបម្រើម្នាក់នេះមិនមែនភ្ញាក់ផ្អើលព្រោះឮថាខ្ញុំនឹងចេញចូលផ្ទះនេះច្រើនខែទេដឹង?»